# ច្បាប់

# ស្តីពី

# ការកែតម្រូវនៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០០៩



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់កែតម្រូវនេះ គឺជាច្បាប់ហិរញ្ញវត្ថុបន្ថែមលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលមានគោលបំណងផ្តល់ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល សម្រាប់ជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់គម្រោងវិនិយោគ មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យទាំងពីរនេះ ។

## ជំពូកទី ២
## ប្រភពធនធាន និងការគ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម

**មាត្រា ២.–**

អនុញ្ញាតឱ្យបង្កើត “មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម” ដែលត្រូវគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មូលនិធិនេះ មានគោលដៅផ្តល់ឥណទានរយៈពេលខ្លី មធ្យម និងវែង សម្រាប់ទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

**មាត្រា ៣.–**

ប្រភពធនធាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម រួមមាន ៖

-ហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាល តាមរយៈច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬ/និង តាមរយៈច្បាប់កែតម្រូវនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

Kol

-ការចូលរួមវិភាគទានពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗទៀត ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៥.-**

អនុម័តឥណទានពិសេសចំនួន ៧២.០០០.០០០.០០០៛ (ចិតសិបពីរពាន់លានរៀល) បន្ថែមលើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ជាធនធានដំបូង សម្រាប់មូល-និធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។ ឥណទានពិសេសនេះមានប្រភពហិរញ្ញប្បទានមកពីប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣

## ការកំណត់រយៈពេលអាទិភាពសម្រាប់លើកលែងពន្ធលើប្រាក់ចំណេញ ដល់គម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ក្នុងវិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម

**មាត្រា ៦.-**

គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ត្រូវទទួលបានការលើកទឹកចិត្ត ដោយទទួលបានរយៈពេលអាទិភាពនៃការលើកលែងពន្ធលើប្រាក់ចំណេញចំនួន ៣ (បី)ឆ្នាំ ។ សកម្មភាពវិនិយោគក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL
5/6L /
ksl

ដែលទទួលបានការលើកទឹកចិត្តនេះ ត្រូវកំណត់ដោយអនុក្រឹត្យពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីវិនិយោគ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/០៦០៩/០១១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៦១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន